**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**
**នាយកដ្ឋានកិច្ចការអាស៊ាន**
លេខ: ០៥/២០២២

ថ្ងៃអង្គារ១០រោចខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ នឹងរៀបចំកិច្ចសន្ទនាមន្ត្រីការពារជាតិវេទិកាតំបន់អាស៊ាន (ARF DOD) ដែលនឹងប្រព្រឹត្តទៅ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។ កិច្ចសន្ទនានេះ នឹងដឹកនាំដោយ**ឯកឧត្តម ឧត្តមសេនីយ៍ឯក ឡៃ ចិន្តា** អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នាយក នាយកដ្ឋានកិច្ចការអាស៊ាន ដោយមានការផ្តល់សុន្ទរកថាគន្លឹះស្វាគមន៍ដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រោមមូលបទ "សាមគ្គីដើម្បីសន្តិសុខប្រកបដោយសុខដុម"។

កិច្ចសន្ទនាមន្ត្រីការពារជាតិវេទិកាតំបន់អាស៊ាន នឹងមានការចូលរួមពីបណ្តាប្រទេសសមាជិកអាស៊ានទាំង១០ និងប្រទេសក្រៅអាស៊ានដែលជាសមាជិកវេទិកាតំបន់អាស៊ាន និងដៃគូអាស៊ាន ដូចជា អូស្ត្រាលី បង់ក្លាដេស កាណាដា ចិន ឥណ្ឌា ជប៉ុន នូវែលហ្សេឡង់ សាធារណរដ្ឋកូរ៉េ រុស្ស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ម៉ុងហ្គោលី ប៉ាគីស្ថាន ប៉ាពូញូវហ្គីនេ ស្រីលង្កា ទីម័រខាងកើត សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលនឹងពិភាក្សាលើប្រធានបទចំនួន៣ ដូចជា៖

**១.តួនាទីស្ថាប័នការពារជាតិក្នុងការគាំទ្រការស្តារឡើងវិញបន្ទាប់ពីកូវីដ១៩**

**២.ពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងការពារជាតិក្រោយវិបត្តិកូវីដ១៩**

**៣.ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការការពារជាតិក្នុងតំបន់**

**នាយកដ្ឋានកិច្ចការអាស៊ាន**